# សន្និបាត

## ត្រួតពិនិត្យលទ្ធផលការងារប្រចាំឆ្នាំ២០២៥
## និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ

ថ្ងៃពុធ ព្រហស្បតិ៍ ២-៣រោច ខែមាឃ ឆ្នាំម្សាញ់ ព.ស.២៥៦៩
ប៉ៃលិន ថ្ងៃទី៤-៥ ខែកុម្ភៈ ឆ្នាំ២០២៦

# បទអន្តរាគមន៍

## ប្រធានបទ៖ ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែង គ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

បង្ហាញដោយ លោកជំទាវ បាន ស្រីមុំ

អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន



# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ក្នុងរយៈពេល៣ទសវត្សកន្លងមកនេះ ក្រោមម្លប់ដ៏ត្រជាក់ នៃសន្តិភាពពេញផ្ទៃប្រទេស និងស្ថេរភាពនយោបាយដ៏រឹងមាំ ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាស្ថាបនិកអគ្គមគ្គុទេសក៍ឯក និងជាប្រតិបត្តិករនៃនយោបាយ **ឈ្នះ! ឈ្នះ!** រក្សាបានសុខសន្តិភាព ស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចដែលជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន និងជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ រួមទាំងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

**សម្តេចតេជោ** តែងតែយកចិត្តទុកដាក់គាំទ្រ និងជំរុញការអភិវឌ្ឍ គោលនយោបាយ លើកកម្ពស់សមភាពយេនឌ័រ ដែលសម្រេចបាន សមិទ្ធផលគួរជាទីមោទន និងជាប្រយោជន៍ ពុំអាចកាត់ថ្លៃបាន សម្រាប់ស្ត្រីកម្ពុជាយើង។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ក្នុងនាមស្ត្រីកម្ពុជាទូទាំងប្រទេស នាងខ្ញុំសូមសម្តែងនៅអំណរគុណ និងការដឹងគុណ ដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោ** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ដែលសម្តេច ត្រូវបានប្រសិទ្ធនាមជាបិតាសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ "**ស្ត្រី**" ដោយបានដាក់ចេញ និង អភិវឌ្ឍគោលនយោបាយសមភាពយេនឌ័រនៅកម្ពុជា ដោយមានប្រសិទ្ធភាពតាមយុទ្ធសាស្ត្រចតុកោណទាំងបួន ដំណាក់កាល ដែលបានកំណត់ "**ស្ត្រី**" ជាឆ្អឹងខ្នង នៃសេដ្ឋកិច្ច និងសង្គម នឹងបានបង្កើតឱ្យមានស្ត្រី កាន់តែច្រើនឡើងនៅក្នុងថ្នាក់ដឹកនាំធ្វើសេចក្តីសម្រេចចិត្ត និងជាតំណាងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ " **បុរសធ្វើអ្វីបាន ស្ត្រីក៏អាចធ្វើបានដូចគ្នា** "



# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃប៉ិនប្រសប់ និងចក្ខុវិស័យវែងឆ្ងាយរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី **សម្តេច** បានប្តេជ្ញា ពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអរិយធម៌ខ្ពង់ខ្ពស់ប្រកបដោយសីលធម៌ល្អ និងបរិយាបន្ន ក្នុងនោះ “**ស្ត្រីគឺជាស្នូល**” និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍជាតិ។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ចំណែកទស្សនៈសកលវិញ មានការបញ្ជាក់យ៉ាងច្បាស់ថា “**សិទ្ធិស្ត្រី ជាសិទ្ធិមនុស្ស**” ការថ្លែងសារគាំទ្រដល់ស្ត្រីតែមួយមុខ គឺមិនគ្រប់គ្រាន់ទេ ត្រូវគិតគូរយកចិត្តទុក ដាក់ទាំងផ្នែកស្មារតី សម្ភារៈដល់ស្ត្រី គឺពិតជាមានភាពចាំបាច់បំផុត។ ការផ្តល់ភាពអង់អាចមានន័យថា ត្រូវផ្តល់សិទ្ធិ និងឱកាសពេញលេញដល់ស្ត្រីផងដែរ។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃប៉ិនប្រសប់ និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី **សម្តេច** បានប្តេជ្ញាពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអរិយធម៌ខ្ពង់ខ្ពស់ប្រកប ដោយសិលធម៌ល្អ និងបរិយាបន្នក្នុងនោះ “**ស្ត្រីគឺជាស្នូល**” និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍជាតិ។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ដើម្បីភាពជាអ្នកដឹកនាំទទួលបានជោគជ័យទាំងស្ត្រីថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ការចូលរួមពេញលេញ ក្នុងវិស័យនយោបាយសេដ្ឋកិច្ច និងសង្គម ក្នុងន័យនេះ ដើម្បីសម្រេចបាននូវបេសកកម្មនេះ បានដោយជោគជ័យ លុះត្រាតែស្ត្រី មានឱកាសស្មើៗគ្នា ទាំងនៅក្នុងភាពជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្ត។ អ្វីដែលកម្ពុជាបានកំពុងអភិវឌ្ឍ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវខ្ពស់របស់យើង ចំពោះការប្តេជ្ញាចិត្តថ្នាក់តំបន់ និងសកលលើសមភាពយេនឌ័រ ការផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់ ភាពជាអ្នកដឹកនាំរបស់ស្ត្រីជាពិសេសស្ត្រីនៅថ្នាក់ក្រោមជាតិ។

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

សូមបញ្ជាក់ថា ការផ្តល់ភាពអង់អាចសម្រេចបានអាស្រ័យលើប្រទេសមានសន្តិភាព បើគ្មានសន្តិភាព គឺគ្មានអ្វីៗទាំងអស់។ ដើម្បីលើកកម្ពស់ស្ត្រីនៅថ្នាក់មូលដ្ឋាន យើងត្រូវពិនិត្យទិដ្ឋភាពទូទៅ ចំពោះស្ត្រីនៅក្នុងវិស័យរដ្ឋ និងនយោបាយជាង៥០% ដូច្នេះបើយើងចូលរួមលើកទឹកចិត្តដល់ស្ត្រីនៅថ្នាក់មូលដ្ឋានត្រូវមានចិត្តទូលាយ ត្រូវផ្តល់ទំនុកចិត្តទាំងការគ្រប់គ្រង និងមានសិទ្ធការសម្រេចចិត្តក្នុងការដឹកនាំនឹងត្រូវទទួលស្គាល់ថា ស្ត្រីនៅមូលដ្ឋាន ក៏មានឆន្ទៈនយោបាយខ្លាំង ទាំងការអនុវត្តផ្ទាល់នៅមូលដ្ឋាន និងការងារទំនាក់ទំនងការទូត "**បុរសអាចធ្វើអ្វីបាន ស្ត្រីក៏អាចធ្វើបានដូចគ្នា**"

# ការលើកកម្ពស់តួនាទីស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ប៉ុន្តែស្ត្រីអាចធ្វើបានលើសពីបុរស គឺនៅចំនុចតូចៗជាច្រើន បន្ទាប់សន្សំដែល បុរសធ្វើមិនបាន ប៉ុន្តែចរឹកស្ត្រីពីកំណើតតែម្តងគឺ៖ ស្ត្រីក្រៅពីការងារ អ្នកដឹកនាំ អ្នកនយោបាយ ស្ត្រីជាមេផ្ទះ ជាម្តាយ ជាបង្គោលឆ្អឹងខ្នងដ៏សំខាន់របស់ក្រុមគ្រួសារ មិនអាចខ្វះបាន។

# សូមអរគុណ !!!